ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ២០១៩ ....សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១២

## ប្រកាស
## ស្តីពីការផ្ទេរឥណទានថវិកា

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ ០៤អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៧៧អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្ទេរឥណទានថវិកា
- តាមការចាំបាច់ដើម្បីអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣

## សម្រេច

**ប្រការ១.-** ត្រូវបានប្រតិបត្តិនៅក្នុងវង្វង់ថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣ នូវការផ្ទេរឥណទានថវិកា ដូចមានបញ្ជាក់ក្នុងតារាងខាងក្រោមនេះ ៖

ឯកតា លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ | និយ័តកម្ម | | ឥណទានថ្មីក្រោយនិយ័តកម្ម |
|---|---|---|---|---|---|---|---|
| | | | | | កើន | ថយ | |
| | | | និយ័តកម្មចេញ | | | | |
| | | | ៩៩ - ចំណាយមិនទាន់បែងចែក | | | 1 290 593 | |
| ៦៦ | | | បន្ទុកហិរញ្ញវត្ថុ(ការប្រាក់) | 256 000 | - | 256 000 | 0 |
| ៦៥ | | | ឧបត្ថម្ភកធនដល់រាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ | 333 093 | - | 333 093 | 0 |
| ០៩ | ០៩១ | | ចំណាយត្រៀមបម្រុង | 422 333 | - | 300 000 | 122 333 |
| ១៦ | | | ការទូទាត់ប្រាក់ខ្ចីនិងបំណុលប្រហាក់ប្រហែល | 280 000 | - | 280 000 | 0 |
| ២៧ | | | អចលកម្មហិរញ្ញវត្ថុផ្សេងៗ | 121 500 | - | 121 500 | 0 |
| | | | និយ័តកម្មចូល | | | | |
| | | | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | | 1 290 593 | | |
| ៦១ | ៦១៥ | ៦១៥៣ | ការថែទាំ និងជួសជុលផ្លូវ ផ្លូវលំ ស្ពាន និងលូ | 0 | 250 000 | - | 250 000 |
| ៦៦ | | | បន្ទុកហិរញ្ញវត្ថុ(ការប្រាក់) | 0 | 256 000 | - | 256 000 |
| ៦៥ | ៦៥១ | ៦៥១១ | ឧបត្ថម្ភកធនដល់រាជធានី ខេត្ត | 0 | 70 270 | - | 70 270 |
| ៦៥ | ៦៥១ | ៦៥១២ | ឧបត្ថម្ភកធនដល់ក្រុង ស្រុក | 0 | 58 405 | - | 58 405 |
| ៦៥ | ៦៥១ | ៦៥១៣ | ឧបត្ថម្ភកធនដល់ឃុំ សង្កាត់ | 0 | 204 418 | - | 204 418 |
| ៦៣ | ៧០៩ | | ការសងនិងការបង្វិលវិញ | 0 | 50 000 | - | 50 000 |
| ១៦ | | | ការទូទាត់ប្រាក់ខ្ចីនិងបំណុលប្រហាក់ប្រហែល | 0 | 280 000 | - | 280 000 |
| ២៧ | ២៧១ | | ការឲ្យខ្ចី | 0 | 121 500 | - | 121 500 |

**ប្រការ២.-** ឥណទានថវិកាដែលបានផ្ទេរក្នុងប្រការ១ ខាងលើនេះ ត្រូវបានអនុញ្ញាតឲ្យបំពេញបន្ថែមទៅក្នុងសៀវភៅថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣។

**ប្រការ៣.-** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះ។ ៤

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន**
- អគ្គនាយកដ្ឋានរតនាគារជាតិ
- នាយកដ្ឋានពាក់ព័ន្ធ
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ